# កិច្ចព្រមព្រៀងទីក្រុងលីសបោន
# សម្រាប់កិច្ចការពារការហៅឈ្មោះតាមប្រភពទំនិញ
# និងការចុះបញ្ជីអន្តរជាតិ

## ចុះថ្ងៃទី ៣១ ខែកញ្ញា ឆ្នាំ១៩៥៨
## ដែលបានកែប្រែ នៅទីក្រុងស្តុកហូម ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៦៧
## និងបានធ្វើវិសោធនកម្មចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៧៩

## មាត្រា ១
## [ ការបង្កើតសហភាពពិសេស កិច្ចការពារការហៅឈ្មោះតាមប្រភពទំនិញ ដែលបាន ចុះបញ្ជីនៅការិយាល័យអន្តរជាតិ ][1]

(១) ប្រទេសទាំងឡាយដែលកិច្ចព្រមព្រៀងនេះអនុវត្ត បង្កើតជាសហភាពពិសេសមួយ ក្នុងក្របខ័ណ្ឌសហភាពដើម្បីការពារកម្មសិទ្ធិឧស្សាហកម្ម ។

(២) ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ប្រទេសទាំងនេះសន្យាការពារក្នុងដែលនដីរបស់ខ្លួន ការហៅឈ្មោះតាមប្រភពទំនិញរបស់ប្រទេសសហភាពពិសេសដទៃទៀត ដែលត្រូវបានទទួលស្គាល់និងការពារដូចប្រទេសដើមនិងត្រូវបានចុះបញ្ជីនៅការិយាល័យអន្តរជាតិកម្មសិទ្ធិបញ្ញា(តទៅហៅថា "ការិយាល័យអន្តរជាតិ" ឬ "ការិយាល័យ") ដូចដែលបានចែងក្នុងអនុសញ្ញាបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក(តទៅហៅថា"អង្គការ" ) ។

## មាត្រា ២
## [ និយមន័យនៃសញ្ញាណការហៅឈ្មោះតាមប្រភពទំនិញ និងប្រទេសដើម ]

(១)នៅក្នុងកិច្ចព្រមព្រៀងនេះ " **ការហៅឈ្មោះតាមប្រភពទំនិញ** " សំដៅដល់ការកំណត់ភូមិសាស្ត្រនៃប្រទេសមួយ តំបន់មួយ ឬទីតាំងមួយ សម្រាប់កំណត់ផលិតផលមួយ

[1]មាត្រាទាំងឡាយត្រូវបានដាក់ចំណងជើងដើម្បីជួយសម្រួលការកំណត់អត្តសញ្ញាណ។ គ្មានចំណងជើងនៅក្នុងអត្ថបទជាភាសាបារាំងដែលបានចុះហត្ថលេខា។ ចំណង់ជើងនៃមាត្រា៥និងមាត្រា៦ត្រូវបានផ្លាស់ប្តូរបើប្រៀបធៀបជាមួយការបោះពុម្ពផ្សាយលើកមុន។

ដែលកើតចេញពីទីតាំងនោះ ដែលគុណភាពឬលក្ខណៈរបស់ផលិតផលនោះផ្សាភ្ជាប់ទាំងស្រុង ឬជាពិសេសទៅនឹងបរិស្ថានភូមិសាស្ត្រ ដែលរួមមានកត្តាធម្មជាតិនិងកត្តាមនុស្ស ។

(២) ប្រទេសដើមជាប្រទេសឬជាតំបន់ឬជាទីតាំងដែលស្ថិតនៅក្នុងប្រទេសនោះដែលមានឈ្មោះបង្កើតបានជាការហៅឈ្មោះតាមប្រភពទំនិញ ដែលបានផ្តល់កិត្តិស័ព្ទដល់ផលិតផល ។

## មាត្រា ៣
## [ ខ្លឹមសារនៃកិច្ចការពារ ]

កិច្ចការពារត្រូវបានធានាប្រឆាំងនឹងការរំលោភបំពានឬការត្រាប់តាមណាមួយ ទោះបីប្រភពទំនិញពិតត្រូវបានចង្អុលបង្ហាញក៏ដោយ ឬក៏ការហៅតាមប្រភពទំនិញនោះត្រូវបានប្រើប្រាស់នៅក្នុងទម្រង់បកប្រែ ឬអមដោយពាក្យដូចជា " ប្រភេទ "" បែប ""របៀប" " ត្រាប់តាម" ឬទម្រង់ប្រហាក់ប្រហែល។

## មាត្រា ៤
## [ កិច្ចការពារតាមអត្ថបទផ្សេងៗទៀត ]

បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ មិនត្រូវបដិសេធកិច្ចការពារដែលបានផ្តល់ឱ្យចំពោះការហៅឈ្មោះតាមប្រភពទំនិញរបស់ប្រទេសនីមួយៗនៃសហភាពពិសេសតាមលិខិតុបករណ៍អន្តរជាតិផ្សេងទៀតដូចជាអនុសញ្ញាទីក្រុងប៉ារីសចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣ ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម និងការកែប្រែបន្តបន្ទាប់ព្រមទាំងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីតចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ១៨៩១ ស្តីពីការបង្ក្រាបការបញ្ជាក់ឈ្មោះខុសឬបំភាន់នូវប្រភពទំនិញនិងការកែប្រែបន្តបន្ទាប់ឬតាមច្បាប់ជាតិ ឬសេចក្តីសម្រេចរបស់តុលាការ ។

## មាត្រា ៥
## [ ការចុះបញ្ជីអន្តរជាតិ ការបដិសេធ សេចក្តីជូនដំណឹង ការប្រើប្រាស់ ដោយអនុគ្រោះក្នុងរយៈពេលកំណត់ ]

(១) ការចុះបញ្ជីការហៅឈ្មោះតាមប្រភពទំនិញ ត្រូវធ្វើឡើងនៅការិយាល័យអន្តរជាតិតាមការស្នើសុំរបស់អាជ្ញាធរនៃប្រទេសទាំងឡាយរបស់សហភាពពិសេស ក្នុងនាមជារូបវន្តបុគ្គលឬជានីតិបុគ្គលសាធារណៈឬឯកជន ដែលមានសិទ្ធិប្រើប្រាស់ការហៅឈ្មោះតាមប្រភពទំនិញនេះ ដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួន ។

(២) ការិយាល័យអន្តរជាតិ ត្រូវជូនដំណឹងដោយមិនបង្អង់ទៅអាជ្ញាធរនៃប្រទេសនានារបស់សហភាពពិសេសនិងត្រូវបោះពុម្ពផ្សាយការចុះបញ្ជីនេះក្នុងព្រឹត្តិប័ត្រ។

(៣) អាជ្ញាធររបស់ប្រទេសណាមួយ អាចប្រកាសថាខ្លួនមិនអាចធានាការពារការហៅឈ្មោះតាមប្រភពទំនិញ ពេលដែលបានទទួលដំណឹងអំពីការចុះបញ្ជី ប៉ុន្តែនៅពេលដែលសេចក្តីប្រកាសរបស់អាជ្ញាធរ ត្រូវបានជូនដំណឹងទៅការិយាល័យអន្តរជាតិអមដោយការបញ្ជាក់ហេតុផលក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងអំពីការចុះបញ្ជីហើយឱ្យតែសេចក្តីប្រកាសនេះ មិនប៉ះពាល់ដល់ទម្រង់ផ្សេងទៀតនៃកិច្ចការពារការហៅឈ្មោះតាមប្រភពទំនិញក្នុងប្រទេសពាក់ព័ន្ធដែលម្ចាស់ការហៅឈ្មោះ អាចមានសិទ្ធិទាមទារតាមមាត្រា៤ខាងលើ ។

(៤) អាជ្ញាធរទាំងឡាយនៃប្រទេសសហភាព មិនអាចជំទាស់ចំពោះសេចក្តីប្រកាសនេះបន្ទាប់ពីផុតរយៈពេល១(មួយ)ឆ្នាំដូចមានចែងនៅក្នុងកថាខណ្ឌខាងលើ។

(៥) ការិយាល័យអន្តរជាតិ ត្រូវជូនដំណឹងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានទៅអាជ្ញាធរនៃប្រទេសដើមអំពីសេចក្តីប្រកាសណាមួយ ដែលអាជ្ញាធរនៃប្រទេសមួយផ្សេងទៀតបានធ្វើតាមលក្ខខណ្ឌនៃកថាខណ្ឌទី(៣)។ នៅពេលដែលអាជ្ញាធរជាតិរបស់ខ្លួនបានទទួលដំណឹងអំពីសេចក្តីប្រកាសដែលប្រទេសមួយផ្សេងទៀតបានធ្វើភាគីពាក់ព័ន្ធ នៅក្នុងប្រទេសផ្សេងទៀតនោះ អាចប្រើប្រាស់ឧបាស្រ័យតាមផ្លូវតុលាការឬរដ្ឋបាលទាំងអស់ ដែលបានបើកជូនពលរដ្ឋនៃប្រទេសនោះ ។

(៦) ប្រសិនបើ ការហៅឈ្មោះមួយត្រូវបានការពារក្នុងប្រទេសមួយ ដោយអនុលោមតាមសេចក្តីជូនដំណឹងនៃការចុះបញ្ជីអន្តរជាតិ ដែលភាគីទី៣បានប្រើប្រាស់រួចហើយក្នុងប្រទេសនោះចាប់ពីកាលបរិច្ឆេទមុនសេចក្តីជូនដំណឹងនេះ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសខាងលើមានសិទ្ធិផ្តល់ឱ្យភាគីទី៣នេះ នូវរយៈពេលមិនឱ្យលើសពី២(ពីរ)ឆ្នាំដើម្បីបញ្ចប់ការប្រើប្រាស់នេះក្នុងលក្ខខណ្ឌ ដែលអាជ្ញាធរមានសមត្ថកិច្ចជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីរឿងនេះក្នុងរយៈពេល៣(បី)ខែ បន្ទាប់ពីផុតកំណត់រយៈពេល១(មួយ)ឆ្នាំដូចមានចែងក្នុងកថាខណ្ឌទី(៣)ខាងលើ ។

## មាត្រា ៦

## [ ការសន្មត់ចំពោះការហៅឈ្មោះដែលបានការពារ ដែលមិនអាចក្លាយជានាមទូទៅ ]

ការហៅឈ្មោះមួយ ដែលត្រូវបានការពារក្នុងប្រទេសមួយនៃសហភាពពិសេសតាមនីតិវិធីនៃមាត្រា៥ នៅក្នុងប្រទេសនោះ មិនត្រូវសន្មត់ថាបានក្លាយជានាមទូទៅដរាបណាការហៅឈ្មោះនេះ ត្រូវបានការពារជាការហៅឈ្មោះតាមប្រភពទំនិញក្នុងប្រទេសដើម ។

## មាត្រា ៧

## [រយៈពេលសុពលភាពនៃការចុះបញ្ជីកម្រៃ]

(១) ដោយអនុលោមតាមមាត្រា៥ ការចុះបញ្ជីនៅការិយាល័យអន្តរជាតិមានអានុភាពការពាររហូត តាមអត្ថន័យនៃមាត្រាខាងលើ ដោយមិនចាំបាច់ចុះបញ្ជីសារជាថ្មីឡើយ ។

(២) ត្រូវបង់តែម្តងគត់ចំពោះការចុះបញ្ជីការហៅឈ្មោះតាមប្រភពទំនិញនីមួយៗ។

## មាត្រា ៨

## [ បណ្តឹង ]

(១) បណ្តឹងដើម្បីការពារការហៅឈ្មោះតាមប្រភពទំនិញ អាចត្រូវបានធ្វើក្នុងប្រទេសនីមួយៗនៃសហភាពពិសេស តាមបទប្បញ្ញត្តិនៃច្បាប់ជាតិនីមួយៗ:

១. ដោយអាជ្ញាធរមានសមត្ថកិច្ច ឬតាមសំណើររបស់ព្រះរាជអាជ្ញា

២. ដោយភាគីដែលពាក់ព័ន្ធណាមួយដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល ទោះបីជាសាធារណៈឬឯកជន ។

## មាត្រា ៩

## [ សន្និបាតនៃសហភាពពិសេស ]

(១) (ក) សហភាពពិសេសត្រូវមានសន្និបាតមួយដែលចូលរួមដោយប្រទេសទាំងឡាយដែលបានផ្តល់សច្ចាប័ន ឬបានចូលជាសមាជិកនៃច្បាប់នេះ ។

(ខ) រដ្ឋាភិបាលនៃប្រទេសនីមួយៗត្រូវតំណាងដោយប្រតិភូមួយរូបដែលអាចអមដោយប្រតិភូស្តីទីទីប្រឹក្សា និងអ្នកជំនាញមួយចំនួន ។

(គ) ការចំណាយរបស់គណៈប្រតិភូនីមួយៗជាបន្ទុករបស់រដ្ឋាភិបាលដែលបានតែងតាំងគណៈប្រតិភូនេះ។

(២) (ក) សន្និបាតត្រូវ:

(i) ពិភាក្សារាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការរក្សាការអភិវឌ្ឍន៍នៃសហភាពពិសេស និងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ

(ii) ណែនាំអំពីការរៀបចំសន្និសីទកែប្រែជូនការិយាល័យអន្តរជាតិដោយពិចារណាលើមតិយោបល់នៃប្រទេសទាំងឡាយនៃសហភាពពិសេសដែលមិនបានផ្តល់សច្ចាប័នឬមិនបានចូលជាសមាជិកនៃច្បាប់នេះ

(iii) កែប្រែបទបញ្ជា ដែលរួមមានការកំណត់កម្រៃដែលមានចែងក្នុងមាត្រា ៧(២) និងកម្រៃផ្សេងទៀតដែលទាក់ទងនឹងការចុះបញ្ជីអន្តរជាតិ

(iv) ពិនិត្យនិងអនុម័តរបាយការណ៍ និង សកម្មភាពរបស់អគ្គនាយកនៃអង្គការ(តទៅហៅថា"អគ្គនាយក")ដែលទាក់ទងនឹងសហភាពពិសេសហើយណែនាំតាមការចាំបាច់ដល់អគ្គនាយកចំពោះបញ្ហាទាំងឡាយក្នុងសមត្ថកិច្ចរបស់សហភាពពិសេស

(v) កំណត់កម្មវិធីនិងអនុម័តថវិកាពីរឆ្នាំម្តងនៃសហភាពពិសេសនិងអនុម័តការបិទបញ្ជីគណនី

(vi) អនុម័តបទបញ្ជាហិរញ្ញវត្ថុរបស់សហភាពពិសេស

(vii) បង្កើតគណៈកម្មាធិការជំនាញនិងក្រុមការងារដែលចាំបាច់ដើម្បីសម្រេចគោលបំណងរបស់សហភាពពិសេស

(viii) កំណត់ឱ្យចូលរួមក្នុងកិច្ចប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ចំពោះប្រទេសដែលមិនមែនជាសមាជិកនៃសហភាពពិសេសអង្គការអន្តររដ្ឋាភិបាលនិងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល

(ix) អនុម័តវិសោធនកម្មមាត្រា៩ ដល់មាត្រា១២

(x) ចាត់វិធានការសមស្របផ្សេងទៀតដើម្បីសម្រេចគោលបំណងរបស់សហភាពពិសេស

(xi) បំពេញមុខងារផ្សេងទៀតដែលស្រមតាមកិច្ចព្រមព្រៀងនេះ ។

(ខ) ចំពោះបញ្ហាដែលពាក់ព័ន្ធផងដែរដល់ប្រយោជន៍របស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ សន្និបាត ត្រូវសម្រេចបន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ ។

(៣) (ក) ប្រទេសនីមួយៗដែលជាសមាជិកនៃសន្និបាតមានសំលេងឆ្នោតតែមួយ ។

(ខ ) កូរ៉ុមនៃសន្និបាតត្រូវមានចំនួនពាក់កណ្តាលនៃប្រទេសដែលជាសមាជិក ។

(គ) លើកលែងតែបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ខ)ក្នុងសម័យប្រជុំនីមួយៗប្រសិនបើចំនួនប្រទេសតំណាងមានតិចជាង១/២(មួយភាគពីរ) ប៉ុន្តែស្មើឬច្រើនជាងប្រទេសជាសមាជិកសន្និបាតចំនួន១/៣(មួយភាគបី) សន្និបាតអាចធ្វើការសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះត្រូវមានអានុភាពអនុវត្តតែក្នុងករណីដែលបានបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម។ ការិយាល័យអន្តរជាតិ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះទៅប្រទេសដែលជាសមាជិកទាំងឡាយនៃសន្និបាត ដែលអវត្តមានហើយត្រូវអញ្ជើញប្រទេសទាំងនេះ ឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរឬបោះឆ្នោតអនុប្បវាទក្នុងរយៈពេល៣(បី)ខែចាប់ពីថ្ងៃជូនដំណឹង។ បើផុតរយៈពេលនេះប្រសិនបើ ចំនួននៃប្រទេសដែលបានបោះឆ្នោតឬបោះឆ្នោតអនុប្បវាទស្មើនឹងចំនួនប្រទេសដែលខ្វះសម្រាប់កូរ៉ុមក្នុងសម័យប្រជុំ ការសម្រេចនេះត្រូវមានអានុភាព ឱ្យតែគ្រប់សំលេងភាគច្រើនដែលត្រូវការ។

(ឃ) លើកលែតែបទប្បញ្ញត្តិនៃមាត្រា១២(២) សេចក្តីសម្រេចរបស់សន្និបាតទាមទារសំលេង២/៣(ពីរភាគបី)នៃសំលេងឆ្នោតដែលបានបោះ។

(ង) អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ ។

(ច) ប្រតិភូម្នាក់អាចតំណាង និងបោះឆ្នោតក្នុងនាមប្រទេសតែមួយគត់។

(ឆ) ប្រទេសទាំងឡាយនៃសហភាពពិសេសដែលមិនមែនជាសមាជិកសន្និបាតត្រូវអនុញ្ញាតឱ្យចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍។

(៤) (ក) សន្និបាតត្រូវប្រជុំសាមញ្ញជារៀងរាល់ពីរឆ្នាំម្តង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើគ្មានករណីពិសេសត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងមហាសន្និបាតរបស់អង្គការ។

(ខ) តាមការកោះប្រជុំរបស់អគ្គនាយកសន្និបាតត្រូវប្រជុំវិសាមញ្ញតាមសំណើពីប្រទេសដែលជាសមាជិកសន្និបាតចំនួន១/៤(មួយភាគបួន) ។

(គ) អគ្គនាយកត្រូវរៀបចំរបៀបវារៈនៃសម័យប្រជុំ ។

( ឃ) សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

## មាត្រា ១០

## [ ការិយាល័យអន្តរជាតិ ]

(១) (ក) ការចុះបញ្ជីអន្តរជាតិនិងភារកិច្ចពាក់ព័ន្ធព្រមទាំងកិច្ចការរដ្ឋបាលផ្សេងទៀត

ដែលទាក់ទងនឹងសហភាពពិសេស ត្រូវធ្វើដោយការិយាល័យអន្តរជាតិ ។

(ខ) ជាពិសេស ការិយាល័យអន្តរជាតិត្រូវរៀបចំកិច្ចប្រជុំនិងបំរើការងារជាលេខាធិការដ្ឋានឱ្យសន្និបាតនិងឱ្យគណៈកម្មាធិការជំនាញនិងក្រុមការងារ ដែលសន្និបាតអាចនឹងបង្កើតឡើង ។

(គ) អគ្គនាយក ជានាយកប្រតិបត្តិនៃសហភាពពិសេសហើយជាតំណាងសហភាពពិសេសនេះ ។

(២) អគ្គនាយកនិងបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមរាល់កិច្ចប្រជុំសន្និបាត កិច្ចប្រជុំគណៈកម្មាធិការជំនាញឬក្រុមការងារ ដែលសន្និបាតអាចនឹងបង្កើតឡើង តែគ្មានសិទ្ធិបោះឆ្នោតទេ ។ អគ្គនាយកឬបុគ្គលិកណាម្នាក់ដែលត្រូវតាំងដោយអគ្គនាយកគឺជាលេខាធិការដោយស្វ័យប្រវត្តិរបស់អង្គភាពទាំងនេះ ។

(៣) (ក) តាមសេចក្តីណែនាំរបស់សន្និបាត ការិយាល័យអន្តរជាតិត្រូវរៀបចំសន្និសីទកែប្រែបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមាត្រា៩ដល់មាត្រា១២។

(ខ) ការិយាល័យអន្តរជាតិអាចប្រឹក្សាយោបល់ជាមួយអង្គការអន្តររដ្ឋាភិបាលនិងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធនឹងការរៀបចំសន្និសីទកែប្រែនេះ ។

(គ) អគ្គនាយកនិងបុគ្គលដែលត្រូវបានចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និសីទទាំងនោះ តែ គ្មានសិទ្ធិបោះឆ្នោតទេ។

(៤) ការិយាល័យអន្តរជាតិត្រូវអនុវត្តការងារផ្សេងៗទៀតដែលបានប្រគល់ជូន។

## មាត្រា ១១

## [ហិរញ្ញវត្ថុ]

(១) (ក) សហភាពពិសេសត្រូវមានថវិការបស់ខ្លួន ។

(ខ) ថវិការបស់សហភាពពិសេសរួមមានខ្ទង់ចំណូលនិងខ្ទង់ចំណាយផ្ទាល់របស់សហភាពពិសេស វិភាគទានចំពោះថវិកាសម្រាប់ការចំណាយរួមរបស់សហភាពនិងប្រសិនបើមានចំនួនទឹកប្រាក់ដែលមានក្នុងថវិការបស់សន្និសីទនៃអង្គការ។

(គ) ការចំណាយដែលមិនមែនជាការចំណាយផ្តាច់មុខរបស់សហភាពពិសេស ប៉ុន្តែជាការចំណាយផងដែររបស់សហភាពមួយ ឬសហភាពច្រើនផ្សេងទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការត្រូវចាត់ទុកជាការចំណាយរួមរបស់សហភាព។ ចំណែកនៃ

សហភាពពិសេសក្នុងខ្ទង់ចំណាយរួមនេះ ត្រូវសមាមាត្រនឹងផលប្រយោជន៍ដែលសហភាពពិសេសទទួលបាន ក្នុងចំណាយនោះ ។

(២) ថវិការបស់សហភាពពិសេស ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើលក្ខខណ្ឌសម្របសម្រួលជាមួយថវិកានៃសហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ។

(៣) ថវិការបស់សហភាពពិសេសទទួលបានពីប្រភពនានាដូចខាងក្រោម:

(i) កម្រៃប្រមូលបានពីការចុះបញ្ជីអន្តរជាតិស្របតាមមាត្រា៧(២) ព្រមទាំងកម្រៃនានានិងថ្លៃឈ្នួលសេវាមួផ្សេងៗទៀត ដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិក្នុងនាមសហភាពពិសេស

(ii) ប្រាក់ចំណេញពីការលក់ឬប្រាក់ចំណេញពីលាភការនៃការបោះពុម្ពផ្សាយរបស់ការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងសហភាពពិសេស

(iii) អំណោយ អច្ច័យទាន និងឧបត្ថម្ភធន

(iv) ថ្លៃឈ្នួល ការប្រាក់ និងចំណូលផ្សេងៗទៀត

(v) វិភាគទានរបស់ប្រទេសនានានៃសហភាពពិសេស ក្នុងករណីដែលចំណូលបានមកពីប្រភពទាំងឡាយដូចបានកំណត់ក្នុងចំណុច(i)ដល់ (iv) មិនគ្រប់គ្រាន់សម្រាប់ចំណាយរបស់សហភាពពិសេស។

(៤) (ក) សន្និបាតត្រូវកំណត់ចំនួនកម្រៃដែលចែងក្នុងមាត្រា៧(២) តាមសំណើររបស់អគ្គនាយក ។

(ខ) ចំនួនកម្រៃខាងលើ ត្រូវកំណត់ឱ្យច្បាស់លាស់ដើម្បីឱ្យប្រាក់ចំណូលរបស់សហភាពពិសេស ក្នុងកាលៈទេសៈធម្មតាមានគ្រប់គ្រាន់ដើម្បីទ្រទ្រង់ចំណាយរបស់ការិយាល័យអន្តរជាតិសម្រាប់កាន់កាប់សេវាចុះបញ្ជីអន្តរជាតិ ដោយមិនទាមទារឱ្យបង់វិភាគទានដូចមានចែងក្នុងកថាខណ្ឌ៣(v) ខាងលើនោះឡើយ ។

(៥) (ក) ដើម្បីកំណត់ចំណែកដែលត្រូវបង់វិភាគទាន ដែលចែងក្នុងកថាខណ្ឌ៣(v) ប្រទេសនីមួយៗនៃសហភាពពិសេស ត្រូវស្ថិតនៅក្នុងចំណាត់ថ្នាក់ដូចគ្នាទៅនឹងចំណាត់ថ្នាក់ដែលមានក្នុងសហភាពទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ហើយត្រូវបង់វិភាគទានប្រចាំឆ្នាំរបស់ខ្លួន ដោយផ្អែកលើចំនួនដូចគ្នានៃឯកតាដែលបានកំណត់សម្រាប់ចំណាត់ថ្នាក់នោះនៅក្នុងសហភាពនោះ ។

(ខ) វិភាគទានប្រចាំឆ្នាំនៃប្រទេសនីមួយៗរបស់សហភាពពិសេស ត្រូវមានចំនួនសមាមាត្រទៅនឹងចំនួនសរុប ដែលបានធ្វើវិភាគទានទៅថវិកាប្រចាំឆ្នាំរបស់សហភាពពិសេសដោយប្រទេសទាំងអស់ ដូចនឹងឯកតានៃចំណាត់ថ្នាក់របស់ខ្លួនទៅនឹងចំនួនសរុបនៃឯកតារបស់ប្រទេសដែលបានបង់វិភាគទានទាំងអស់។

(គ) សន្និបាតត្រូវកំណត់កាលបរិច្ឆេទនៃការបង់វិភាគទាន ។

(ឃ) ប្រទេសដែលយឺតយ៉ាវក្នុងការបង់វិភាគទានមិនអាចអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនក្នុងអង្គភាពណាមួយនៃសហភាពពិសេស ប្រសិនបើចំនួនដែលមិនបានបង់ ស្មើឬលើស ចំនួននៃវិភាគទាន ត្រូវបង់ចំនួន២(ពីរ)ឆ្នាំពេញ។ ប៉ុន្តែប្រទេសនេះអាចអនុញ្ញាតឱ្យបន្តអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនក្នុងអង្គភាពនោះបាន ដរាបណាបានផ្តល់ហេតុផលត្រឹមត្រូវពីការយឺតយ៉ាវក្នុងការបង់វិភាគទាន ដោយកាលៈទេសៈពិសេសនិងមិនអាចជៀសវាងបាន។

(ង) ប្រសិនបើ ថវិកាមិនបានអនុម័តមុនពេលចាប់ផ្តើមនៃរយៈពេលហិរញ្ញវត្ថុថ្មី ថវិកានេះត្រូវមានកំរិតដូចគ្នាទៅនឹងថវិកាឆ្នាំមុន ដូចមានចែងក្នុងបទបញ្ជាហិរញ្ញវត្ថុ ។

(៦) តាមបទប្បញ្ញត្តិនៃកថាខណ្ឌទី(៤)(ក) ចំនួនកម្រៃនិងថ្លៃឈ្នួលសេវាកម្មដែលបានមកពីការផ្តល់សេវារបស់ការិយាល័យអន្តរជាតិក្នុងនាមសហភាពពិសេស ត្រូវបានបង្កើតនិងត្រូវបានរាយការណ៍ជូនសន្និបាតដោយអគ្គនាយក។

(៧) (ក) សហភាពពិសេសត្រូវមានមូលនិធិទុនបង្វិលដែលបានទទួលបានពីការបង់ប្រាក់សរុបរួមតែម្តងពីប្រទេសនីមួយៗនៃសហភាពពិសេស។ ប្រសិនបើមូលនិធិនេះមិនគ្រប់គ្រាន់ សន្និបាតអាចសម្រេចបង្កើនមូលនិធិនេះបាន ។

(ខ) ចំនួននៃការបង់ប្រាក់ដំបូងរបស់ប្រទេសនីមួយៗក្នុងមូលនិធិខាងលើឬការបង់ប្រាក់ដំបូងនៃការចូលរួមរបស់ខ្លួនក្នុងការបង្កើនមូលនិធិ ត្រូវសមាមាត្រទៅនឹងវិភាគទាននៃប្រទេសនោះ ដូចសមាជិកនៃសហភាពទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មចូលទៅក្នុងថវិកានៃសហភាពខាងលើ សម្រាប់ឆ្នាំនៃការបង្កើតមូលនិធិនេះឬឆ្នាំនៃការសម្រេចបង្កើនមូលនិធិ ។

(គ) សមាមាត្រ និងលក្ខខណ្ឌនៃការបង់ប្រាក់ត្រូវកំណត់ដោយសន្និបាត តាមសំណើរបស់អគ្គនាយក និងបន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលរបស់អង្គការ ។

(៨) (ក) នៅក្នុងកិច្ចព្រមព្រៀងទីស្នាក់ការ ដែលបានធ្វើជាមួយប្រទេសដែលអង្គការបានដាក់ទីស្នាក់ការ ត្រូវចែងថា នៅពេលដែលមូលនិធិទុនបង្វិលមិនគ្រប់គ្រាន់ ប្រទេសនេះត្រូវបង់ប្រាក់ជាមុន។ ចំនួននៃប្រាក់ដែលត្រូវបង់ជាមុន និងលក្ខខណ្ឌនៃការផ្តល់ការបង់ជាមុនត្រូវកំណត់ដោយកិច្ចព្រមព្រៀងដោយឡែកពីគ្នា រវាងប្រទេសនោះជាមួយអង្គការ។

(ខ) ប្រទេសដែលមានចែងក្នុងអនុកថាខណ្ឌ(ក)និងអង្គការ មានសិទ្ធិបដិសេធកាតព្វកិច្ចបង់ប្រាក់ជាមុន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការបដិសេធនេះមានអានុភាព៣( បី)ឆ្នាំបន្ទាប់ពីដំណាច់ឆ្នាំនៃការជូនដំណឹង ។

(៩) សវនកម្មគណនីត្រូវធ្វើឡើងដោយប្រទេសមួយឬច្រើននៃសហភាពពិសេស ឬដោយសវនករខាងក្រៅដូចមានចែងក្នុងបទបញ្ញាហិរញ្ញវត្ថុ។ សវនករត្រូវតែងតាំងដោយសន្និបាតដោយមានការយល់ព្រមពីសវនករ។

## មាត្រា ១២

## [ ការធ្វើវិសោធនកម្មមាត្រា៩ ដល់ មាត្រា១២]

(១) ការស្នើសុំធ្វើវិសោធនកម្មមាត្រា៩ មាត្រា១០ មាត្រា១១និងមាត្រានេះអាចត្រូវផ្តួចផ្តើមគំនិតដោយប្រទេសសមាជិកណាមួយនៃសន្និបាតឬដោយអគ្គនាយក។ សំណើនេះត្រូវជូនដំណឹងទៅឱ្យប្រទេសជាសមាជិកទាំងឡាយនៃសន្និបាតដោយអគ្គនាយក យ៉ាងហោចណាស់ក្នុងរយៈពេល៦(ប្រាំមួយ) ខែមុនពេលសន្និបាតលើកសំណើនេះមកពិចារណា ។

(២) វិសោធនកម្មមាត្រាទាំងឡាយដូចមានចែងក្នុងកថាខណ្ឌទី(១) ត្រូវអនុម័តដោយសន្និបាត។ការអនុម័តនេះទាមទារឱ្យមានសម្លេងឆ្នោត៣/៤(បីភាគបួន) តែ វិសោធនកម្មមាត្រា៩និងកថាខណ្ឌនេះទាមទារឱ្យមានសម្លេងឆ្នោតចំនួន៤/៥(បួនភាគប្រាំ) ។

(៣) វិសោធនកម្មណាមួយនៃមាត្រាទាំងឡាយ ក្នុងកថាខណ្ឌទី(១) ត្រូវចូលជាធរមានក្នុងរយៈពេលមួយខែ បន្ទាប់ពីអគ្គនាយកទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានធ្វើឡើងស្របតាមដំណើរការរដ្ឋធម្មនុញ្ញរៀងៗខ្លួននៃប្រទេស៣/៤(បីភាគបួន) ដែលជាសមាជិកសន្និបាត នៅពេលដែលសន្និបាតបានអនុម័តទទួលយកវិសោធនកម្ម។ វិសោធនកម្មមាត្រាខាងលើនេះ ហើយដែលត្រូវបានទទួលយកត្រូវមានអានុភាពចងប្រទេសទាំងឡាយដែលជាសមាជិកសន្និបាត នៅពេលដែលវិសោធនកម្មចូលជាធរមាន ឬដែលក្លាយជាសមាជិកសន្និបាតនាពេលក្រោយ។វិសោធនកម្មណាដែលបង្កើន កាតព្វកិច្ចហិរញ្ញវត្ថុចំពោះប្រទេស

នានានៃសហភាពពិសេស ត្រូវមានអានុភាពចងតែប្រទេសណាដែលបានប្រកាសយល់ព្រមវិសោធនកម្មនេះតែប៉ុណ្ណោះ។

## មាត្រា ១៣

### [ បទបញ្ជា ការកែប្រែ ]

(១) សេចក្តីលម្អិតនៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះនឹងត្រូវកំណត់ក្នុងបទបញ្ជា។

(២) កិច្ចព្រមព្រៀងនេះអាចត្រូវបានកែប្រែតាមរយៈសន្និសីទដែលធ្វើឡើងដោយប្រតិភូនៃប្រទេសទាំងឡាយរបស់សហភាពពិសេស។

## មាត្រា ១៤

### [ ការផ្តល់សច្ចាប័នឬការចូលជាសមាជិក ការចូលជាធរមាន ការយោងទៅមាត្រា២៤ នៃអនុសញ្ញាទីក្រុងប៉ារីស(ដែនដី) ការចូលជាសមាជិកនៃច្បាប់ឆ្នាំ១៩៥៨]

(១) ប្រទេសណាមួយនៃសភាពពិសេសដែលបានចុះហត្ថលេខាលើច្បាប់នេះ អាចផ្តល់សច្ចាប័នបាន ហើយ ប្រសិនបើមិនបានចុះហត្ថលេខាទេ អាចចូលជាសមាជិកនៃច្បាប់នេះបាន។

(២) (ក) ប្រទេសណាមួយនៅក្រៅសហភាពពិសេស ដែលជាសមាជិកអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មអាចចូលជាសមាជិកនៃច្បាប់នេះ ហើយក្លាយជាសមាជិកនៃសហភាពពិសេស ។

(ខ) សេចក្តីជូនដំណឹងអំពីការចូលជាសមាជិក ក្នុងដែនដីនៃប្រទេសដែលបានចូលជាសមាជិក ត្រូវធានានូវផលប្រយោជន៍ទាំងឡាយតាមបទប្បញ្ញត្តិខាងលើ ចំពោះការហៅឈ្មោះតាមប្រភពទំនិញដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ នៅពេលចូលជាសមាជិក។

(គ)ប៉ុន្តែក្នុងរយៈពេល១(មួយ)ឆ្នាំ ប្រទេសណាមួយដែលចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ចំពោះការហៅឈ្មោះតាមប្រភពទំនិញដែលបានចុះបញ្ជីរួចហើយនៅការិយាល័យអន្តរជាតិអាចប្រកាសថាខ្លួនមានបំណងប្រើប្រាស់សិទ្ធិដែលមានចែងក្នុងមាត្រា៥(៣)។

(៣) លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន និង ការចូលជាសមាជិក ត្រូវតម្កល់ជូនអគ្គនាយក ។

(៤) បទប្បញ្ញត្តិទាំងឡាយនៃមាត្រា២៤នៃអនុសញ្ញាទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មត្រូវយកមកអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

(៥)　(ក) ចំពោះប្រទេសចំនួន៥(ប្រាំ)ដំបូងដែលបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ច្បាប់នេះត្រូវចូលជាធរមានក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីបានតម្កល់លិខិតុបករណ៍ទី៥ ។

(ខ)　ចំពោះប្រទេសណាមួយផ្សេងទៀត ច្បាប់នេះត្រូវចូលជាធរមានក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងរបស់អគ្គនាយកពីការផ្តល់សច្ចាប័នឬការចូលជាសមាជិក លើកលែងតែ មានការបង្ហាញកាលបរិច្ឆេទបន្ទាប់ក្នុងលិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក។ ក្នុងករណីចុងក្រោយនេះ ច្បាប់នេះត្រូវចូលជាធរមានចំពោះប្រទេសនោះតាមកាលបរិច្ឆេទដែលបានកំណត់។

(៦) ការផ្តល់សច្ចាប័នឬការចូលជាសមាជិក តម្រូវឱ្យទទួលយកជាស្វ័យប្រវត្តិគ្រប់ខនិងទទួលបានផលប្រយោជន៍ទាំងអស់ពីច្បាប់នេះ។

(៧) បន្ទាប់ពីការចូលជាធរមាននៃច្បាប់នេះ ប្រទេសណាមួយអាចចូលជាសមាជិកនៃច្បាប់ដើមចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៥៨នៃកិច្ចព្រមព្រៀងនេះ　តែក្នុងករណីដែលមានការផ្តល់សច្ចាប័នឬការចូលជាសមាជិកនៃច្បាប់នេះ។

## មាត្រា ១៥

## [រយៈពេលនៃកិច្ចព្រមព្រៀង ការប្រកាសដកខ្លួនចេញ]

(១)　កិច្ចព្រមព្រៀងនេះនៅតែចូលជាធរមាន ឱ្យតែ មានប្រទេសយ៉ាងហោចណាស់ចំនួន៥(ប្រាំ)នៅជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ។

(២) ប្រទេសណាមួយ អាចប្រកាសដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ តាមរយៈការជូនដំណឹងទៅអគ្គនាយក។ ការប្រកាសដកខ្លួនចេញនេះ ត្រូវបង្កើតជាការប្រកាសដកខ្លួនចេញផងដែរពីច្បាប់ដើមចុះថ្ងៃទី៣១ខែតុលាឆ្នាំ១៩៥៨នៃកិច្ចព្រមព្រៀងនេះ　ហើយត្រូវប៉ះពាល់តែប្រទេសដែលធ្វើប្រកាសប៉ុណ្ណោះ។ កិច្ចព្រមព្រៀងនេះ នៅតែអនុវត្តនិងមានអានុភាពពេញលេញចំពោះប្រទេសផ្សេងទៀតនៃសហភាពពិសេស ។

(៣)　ការប្រកាសដកខ្លួនចេញត្រូវមានអានុភាពអនុវត្តក្នុងរយៈពេល១(មួយ)ឆ្នាំបន្ទាប់ពីថ្ងៃដែលអគ្គនាយកបានទទួលសេចក្តីជូនដំណឹង ។

(៤)　សិទ្ធិប្រកាសដកខ្លួនចេញដូចមានចែងក្នុងមាត្រានេះ　មិនត្រូវបានអនុវត្តដោយប្រទេសណាមួយមុនផុតរយៈពេល៥(ប្រាំ)ឆ្នាំ　ចាប់ពីកាលបរិច្ឆេទដែលប្រទេសនេះក្លាយជាសមាជិកនៃសហភាពពិសេស ។

## មាត្រា ១៦

## [ច្បាប់ដែលអនុវត្ត]

(១) (ក) ចំពោះទំនាក់ទំនងរវាងប្រទេសនានានៃសហភាពពិសេស ដែលបានផ្តល់សច្ចាប័នឬចូលជាសមាជិកកិច្ចព្រមព្រៀងនេះត្រូវជំនួសច្បាប់ដើម ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៥៨ ។

(ខ) ប៉ុន្តែ ប្រទេសណាមួយនៃសហភាពពិសេស ដែលបានផ្តល់សច្ចាប័នឬចូលជាសមាជិកកិច្ចព្រមព្រៀងនេះ ត្រូវជាប់កាតព្វកិច្ច ដោយច្បាប់ដើមចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៥៨ ចំពោះទំនាក់ទំនងរវាងប្រទេសនានានៃសហភាពពិសេសដែលមិនបានផ្តល់សច្ចាប័ន ឬមិនបានចូលជាសមាជិកកិច្ចព្រមព្រៀងនេះ ។

(២)ប្រទេសទាំងឡាយក្រៅសហភាពពិសេសដែលបានក្លាយជាភាគីកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តកិច្ចព្រមព្រៀងនេះ ចំពោះការចុះបញ្ជីការហៅឈ្មោះតាមប្រភពទំនិញជាអន្តរជាតិ នៅការិយាល័យអន្តរជាតិតាមសំណើរបស់អាជ្ញាធរប្រទេសណាមួយនៃសហភាពពិសេស ដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ ឱ្យតែការចុះបញ្ជីបំពេញតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ចំពោះប្រទេសទាំងនេះ។ ចំពោះការចុះបញ្ជីអន្តរជាតិនៅការិយាល័យអន្តរជាតិ តាមសំណើរបស់អាជ្ញាធរនៃប្រទេសទាំងនេះក្រៅសហភាពពិសេស ដែលបានក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះ ប្រទេសទាំងនេះទទួលស្គាល់ថាជាប្រទេសខាងលើនៃសហភាពពិសេស អាចតម្រូវឱ្យគោរពតាមលក្ខខណ្ឌនៃច្បាប់ដើមចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៥៨ ។

## មាត្រា ១៧

## [ការចុះហត្ថលេខា ភាសា មុខងារនៃការតម្កល់]

(១) (ក) កិច្ចព្រមព្រៀងនេះ ត្រូវចុះហត្ថលេខាលើច្បាប់ចម្លងតែមួយជាភាសាបារាំង ហើយត្រូវតម្កល់ជូនរដ្ឋាភិបាលប្រទេសស៊ុយអ៊ែត ។

(ខ) អត្ថបទផ្លូវការត្រូវធ្វើឡើងដោយអគ្គនាយកជាភាសាផ្សេងទៀតដែលសន្និបាតអាចកំណត់ បន្ទាប់ពីបានប្រឹក្សាយោបល់ជាមួយរដ្ឋាភិបាលពាក់ព័ន្ធនានា។

(២) កិច្ចព្រមព្រៀងនេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខានៅទីក្រុងស្តុកហូមរហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦៨ ។

(៣) អគ្គនាយកត្រូវបញ្ជូនច្បាប់ចម្លង២(ពីរ)ច្បាប់នៃអត្ថបទដែលបានចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ ដែលបញ្ជាក់ថាត្រឹមត្រូវ ដោយរដ្ឋាភិបាលប្រទេសស៊ុយអ៊ែតទៅរដ្ឋាភិបាល

នៃប្រទេសទាំងអស់ក្នុងសហភាពពិសេស និងទៅរដ្ឋាភិបាលនៃប្រទេសណាមួយផ្សេងទៀតតាមការស្នើសុំ។

(៤) អគ្គនាយក ត្រូវចុះបញ្ជីកិច្ចព្រមព្រៀងនេះនៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ។

(៥) អគ្គនាយកត្រូវជូនដំណឹងដល់រដ្ឋាភិបាលនៃប្រទេសទាំងអស់នៃសហភាពពិសេស អំពីការចុះហត្ថលេខា ការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ការចូលជាធរមាននៃបទប្បញ្ញត្តណាមួយនៃកិច្ចព្រមព្រៀងនេះ ការប្រកាសដកខ្លួនចេញ និងសេចក្តីប្រកាសតាមមាត្រា១៥(២)(គ)និង(៤)។

## មាត្រា ១៨

## [អន្តរប្បញ្ញត្តិ]

(១) រហូតដល់ពេលអគ្គនាយកដំបូងចូលកាន់ដំណែង ការយោងក្នុងកិច្ចព្រមព្រៀងនេះដល់ការិយាល័យអន្តរជាតិនៃអង្គការឬដល់អគ្គនាយក ត្រូវចាត់ទុកថាជាការយោងដល់ការិយាល័យនៃសហភាព ដែលបង្កើតឡើងដោយអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មឬនាយករបស់ខ្លួន តាមករណីនីមួយៗ។

(២) ៥(ប្រាំ)ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញាដែលបង្កើតអង្គការ ប្រទេសទាំងឡាយនៃសហភាពពិសេសដែលមិនបានផ្តល់សច្ចាប័នឬមិនបានចូលជាសមាជិកចិ្រព្រមព្រៀងនេះ បើចង់ អាចអនុវត្តសិទ្ធិដូចមានចែងក្នុងមាត្រា៩ដល់មាត្រា១២នៃកិច្ចព្រមព្រៀងនេះហាក់បីដូចជា ប្រទេសទាំងនេះជាប់កាតព្វកិច្ចតាមមាត្រាទាំងនេះដែរ។ ប្រទេសណាមួយដែលចង់អនុវត្តសិទ្ធិនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយក។ ការជូនដំណឹងនេះត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។ ប្រទេសទាំងនេះត្រូវចាត់ទុកជាសមាជិកសន្និបាតរហូតដល់ពេលផុតកំណត់នៃរយៈពេលនេះ។